នស / រកត / ០៩០២/២៣៧

# ព្រះរាជក្រឹត្យ

## ស្តីពី

## សញ្ញាសក្តិ និងឯកសណ្ឋាននៃថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ

៚០៛

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៥៨ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការតែងតាំងអគ្គសវនករ អគ្គសវនកររងនៃអាជ្ញាធរសវនកម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៧១ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរងនៃអាជ្ញាធរសវនកម្មជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

Downloaded from http://www.khmerlaws.com

# ស្រាវស់បន្ទាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតសញ្ញាសក្តិនិងឯកសណ្ឋានសំរាប់សំគាល់អគ្គសវនករ អគ្គសវនកររង អគ្គលេខាធិការ អគ្គលេខាធិការរង នៃអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២ .-**

សញ្ញាសក្តិ និងឯកសណ្ឋាននេះប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី២

## សញ្ញាសក្តិ

**មាត្រា ៣ .-**

សញ្ញាសក្តិសំរាប់អគ្គសវនករ អគ្គសវនកររង អគ្គលេខាធិការ អគ្គលេខាធិការរង នៃអាជ្ញាធរសវនកម្មជាតិត្រូវបានកំណត់ដូចតទៅ :

**១- សំរាប់អគ្គសវនករ**

**ក.សក្តិស្មា** : មានផ្ទៃកម្ចីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់អង្គរពណ៌មាស មានសញ្ញា អាជ្ញាធរសវនកម្មជាតិនៅកណ្តាល និងនៅលើសញ្ញាអាជ្ញាធរសវនកម្មជាតិ មានឡេវរូបព្រះសង្ខារពណ៌មាសមួយ ។ មានជរជាយសន្ទឹកក្បាច់អង្គរពណ៌មាសព័ទ្ធជុំវិញ។ នៅចន្លោះក្បាច់អង្គរ និងក្បាច់ជរជាយ មានខ្សែពួរវេញពណ៌មាសមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គសវនករ និងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្រៅ ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ :

-បាតក្រោមប្រវែង ៦ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

**ខ.សក្តិចុងករអាវ** : មានផ្ទៃកម្ចីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់អង្គរពណ៌មាស និងមានសញ្ញាអាជ្ញាធរសវនកម្មជាតិពណ៌មាសនៅខាងដើម ។ មានជរជាយសន្ទឹកក្បាច់អង្គរពណ៌មាសព័ទ្ធនៅផ្នែកខាងលើ និងចំហៀងខាងមុខ ។ នៅចន្លោះក្បាច់អង្គរ និងក្បាច់ជរជាយ នៅផ្នែកខាងលើ និងចំហៀងខាង

Downloaded from http://www.khmerlaws.com

មុខ មានខ្សែពួរវេញពណ៌មាសមួយឆ្នូត សំរាប់សំគាល់ឋានន្តរសក្តិអគ្គសវនករ ហើយនឹងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្រៅ ។

ខ្នាតសក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានរាងជាប្រលេឡូក្រាម

-បណ្តោយប្រវែង ១០.៥០ សង្ទីម៉ែត្រ

-ទទឹងប្រវែង ៤ សង្ទីម៉ែត្រ

**គ.សក្តិចុងដៃអាវទាំងសងខាង** :មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់អង្គរ ពណ៌មាស និងមានជរជាយសន្ទឹកក្បាច់អង្គរពណ៌មាសនៅជាយផ្នែកខាងលើ និងសងខាង ។ នៅចន្លោះក្បាច់អង្គរ និងក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសមួយឆ្នូត សំរាប់សំគាល់ឋានន្តរសក្តិអគ្គសវនករនៅផ្នែកខាងលើនិងសងខាង ហើយនឹងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្រៅ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាងត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយប្រវែង ៣៣ សង្ទីម៉ែត្រចំពោះបុរស និង ២៥ ទៅ ២៨ សង្ទីម៉ែត្រ ចំពោះនារី អាស្រ័យលើមាឌ

-ទទឹងប្រវែង ១០.៥០ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាប់អគ្គសវនករ មានដូចក្នុងឧបសម្ពន្ធ័ទី ១ នៃព្រះរាជក្រឹត្យនេះ ។

**២. សំរាប់អគ្គសវនកររង អគ្គលេខាធិការ និងអគ្គលេខាធិការរង**

សញ្ញាសក្តិសំរាប់អគ្គសវនកររង អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអាជ្ញាធរសវនកម្មជាតិ ត្រូវបានកំណត់ដូចតទៅ :

**ក.សក្តិស្មា** : មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស មានសញ្ញាអាជ្ញាធរសវនកម្មជាតិផ្នែកខាងលើ និងនៅខាងលើសញ្ញាអាជ្ញាធរសវនកម្មជាតិ មានឡេវរូបព្រះសង្ខារពណ៌មាសមួយ ។ មានជរជាយសន្ទឹកក្បាច់ភ្ញីទេសព័ទ្ធជុំវិញ ។ នៅខាងក្រៅក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសបីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គសវនកររង ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គលេខាធិការ មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គលេខាធិការរង និងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញពីខាងក្នុងនៅចន្លោះក្បាច់ជរជាយ នឹងក្បាច់ភ្ញីទេនេះ ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ :

-បាតក្រោមប្រវែង ៦ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

Downloaded from http://www.khmerlaws.com

**ខ.សក្តិចុងករអាវ** : មានផ្ទៃកម្ពីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានសញ្ញាអាជ្ញាធរសវនកម្មជាតិនៅខាងក្នុង ។ មានជរជាយសន្ទឹកក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធនៅផ្ទៃកខាងលើនិងចំហៀងខាងមុខ ។ នៅខាងក្រៅក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសបីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គសវនកររង ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គលេខាធិការ មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គលេខាធិការរង នឹងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញនៅចន្លោះក្បាច់ជរជាយ នឹងក្បាច់ភ្ញីទេស ។

ខ្នាតសក្តិចុងករអាវត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានរាងជាប្រលេឡូក្រាម
-បណ្តោយប្រវែង ១០.៥០ សង្ទីម៉ែត្រ
-ទទឹងប្រវែង ៤ សង្ទីម៉ែត្រ

**គ.សក្តិចុងដៃអាវទាំងសងខាង** : មានផ្ទៃកម្ពីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានជរជាយសន្ទឹកក្បាច់ភ្ញីទេសពណ៌មាសនៅជាយផ្ទៃកខាងលើនិងសងខាង ។ នៅខាងក្រៅក្បាច់ជរជាយមានខ្សែពួរវេញពណ៌មាសបីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គសវនកររង ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គលេខាធិការ មួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអគ្គលេខាធិការរង និងមានខ្សែពួរវេញពណ៌មាសមួយទៀតព័ទ្ធជុំវិញនៅចន្លោះក្បាច់ជរជាយ និងក្បាច់ភ្ញីទេស ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាងត្រូវបានកំណត់ដូចខាងក្រោមនេះ :

-មានរាងបួនជ្រុងទ្រវែង
-បណ្តោយប្រវែង ៣៣ សង្ទីម៉ែត្រចំពោះបុរស និង ២៥ ទៅ ២៨ សង្ទីម៉ែត្រ ចំពោះនារី អាស្រ័យលើមាឌ
-ទទឹងប្រវែង ១០.៥០ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងករអាវ និងសក្តិចុងដៃអាវ សំរាប់អគ្គសវនកររង មានដូចក្នុងឧបសម្ពន្ធ័ទី ២ សំរាប់អគ្គលេខាធិការ មានដូចក្នុងឧបសម្ពន្ធ័ទី ៣ សំរាប់អគ្គលេខាធិការរង មានដូចក្នុងឧបសម្ពន្ធ័ទី ៤ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកសក្តិស្មា សក្តិចុងករអាវ សក្តិចុងដៃអាវទាំងសងខាងរបស់នារី មានទំហំដូចខាងក្រោមនេះ :

-ចំពោះសក្តិស្មាអាចមានទំហំទទឹងស្មើ ៨០% ៨៥% ឬ ៩០% នៃទំហំសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
-សក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើ ៧០% ទៅ ៧៥% នៃទំហំចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី
-សក្តិករអាវមានទំហំទទឹងស្មើ ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៣
## ប្រភេទឯកសណ្ឋាន និងការប្រើប្រាស់

**មាត្រា ៤.-**

ប្រភេទឯកសណ្ឋានសំរាប់អគ្គសវនករ អគ្គសវនកររង អគ្គលេខាធិការ អគ្គលេខាធិការរងនៃអាជ្ញាធរសវនកម្មជាតិ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

**១-ឯកសណ្ឋានផ្លូវការ**

**-ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាង មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគម្របរាងស្លឹកពោធិខាងលើពីរ ខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិ តាមឋានន្តរសក្តិ អាវបិទឡេវមុខ ដោយមានដាក់ឡេវរូបព្រះសង្ហារពណ៌មាសចំនួន ៧ ។

-ខោជើងវែងពណ៌ស ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**-ចំពោះនារី**

-អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសកតាំង គ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួនប្រាំនិងមានរាងមូលនៅជាយអាវខាងក្រោម ។ ចុងកអាវទាំងសងខាងមានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ គ្មានហោប៉ៅ អាវដៃវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

ឯកសណ្ឋានផ្លូវការមាន ៣ ប្រភេទ :

-ប្រើសំពត់សំឡុយអំពីផាមួងពណ៌តាមថ្ងៃ ចាក់ជើងអំពីសូត្រ ពណ៌ខ្ចីជាងពណ៌សំពត់ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ១ ។

-ប្រើសំពត់សំឡុយអំពីផាមួងពណ៌តាមថ្ងៃ ចាក់ជើងសៃសយពណ៌ផ្ទាទឹនមាស ក្បាច់ជរជើងឯកភាពគ្នាហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ២ ។

-ប្រើសំពត់សំឡុយហូលតាមគោមឯកភាពគ្នាហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ៣ ។

-ស្បែកជើងអេស្កាប៉ាំងឃ្លុបមុខ និងជិតកែងពណ៌ស កាបូបយួរពណ៌ស សំរាប់ពេលព្រឹកដល់ថ្ងៃត្រង់ ។ ស្បែកជើងអេស្កាប៉ាំងឃ្លុបមុខ និងជិតកែងពណ៌ខ្មៅ កាបូបយួរពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

គំរូឯកសណ្ឋានទាំងបុរស ទាំងនារីមានដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

Downloaded from http://www.khmerlaws.com

**២.ឯកសណ្ឋានប្រពៃណីជាតិ**

**-ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគម្របរាងស្លឹកពោធិខាងលើពីរ ខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ អាវបិទមុខដោយមានដាក់ឡេវរូបព្រះសង្ហារពណ៌មាសចំនួន ៧ ។

-សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅដល់ជង្គង់ ។

**-ចំពោះនារី**

-អាវជីបរាងអំពីសូត្រពណ៌ស ដៃអាវវែងត្រឹមភ្នែកគោលដៃ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិត ១.៥ សង្ទីម៉ែត្រ និងត្រង់ស្មាឃ្លាតពីគល់កប្រមាណ ២.៥ សង្ទីម៉ែត្រ ទៅ ៣.០០ សង្ទីម៉ែត្រអាស្រ័យទៅតាមមាឌរបស់នារី គ្មានសក្តិស្មា និង សក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាងតាមឋានន្តរសក្តិ ។

-ពានាក្រមាអំពីសូត្រ ដែលមានផ្ទៃពណ៌ខ្ចីជាងសំពត់ ចាក់ជាយតាមបណ្តោយក្រមា និងចុងជាយទទឹងក្រមាអំពីសូត្រ ពណ៌ចាស់ដូចសំពត់ តាមក្បាច់ឯកភាពគ្នា ឬ ក្រមាសូត្រពណ៌ស៊ីនួនតាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍បុណ្យជាតិ អន្តរជាតិ ដោយប្រើកន្លាស់សំរាប់ខ្ទាស់ក្រមាពានា ជាកន្លាស់អំពីសញ្ញាអាជ្ញាធរសវនកម្មជាតិ ដែលមានទំហំទទឹង ៥ សង្ទីម៉ែត្រ និងកំពស់ ៧ សង្ទីម៉ែត្រ ។

ឯកសណ្ឋានប្រពៃណីមាន ២ ប្រភេទ :

-ឯកសណ្ឋានប្រពៃណី ដែលប្រើសំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ និងពានាក្រមា ហៅថាឯកសណ្ឋានប្រពៃណីប្រភេទលេខ ១ ។

-ឯកសណ្ឋានប្រពៃណីដែលប្រើសំពត់ហូលតាមគោមឯកភាពគ្នា និងពានាក្រមាពណ៌ស៊ីនួន ហៅថា ឯកសណ្ឋានប្រពៃណីប្រភេទលេខ ២ ។

-ស្បែកជើងពណ៌ស និងកាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹកដល់ថ្ងៃត្រង់ ស្បែកជើងពណ៌ខ្មៅ និងកាបូបយួរដៃពណ៌ខ្មៅសំរាប់ពេលល្ងាច ។

រូបគំរូឯកសណ្ឋានប្រពៃណីនេះមានដូចក្នុងឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥.-**

ការប្រើប្រាស់ឯកសណ្ឋាន ត្រូវបានកំណត់ដូចខាងក្រោម :

Downloaded from http://www.khmerlaws.com

-ឯកសណ្ឋានផ្លូវការសំរាប់ប្រើប្រាស់ក្នុងទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ ។

-ឯកសណ្ឋានប្រពៃណីជាតិ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិនិងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការសំបទ្ទាប់**

**ប្រមុខរដ្ឋស្តីទី**

នស/រកត/០៩០២/២៩៤ **ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

បានយកសេចក្តីបង្គំទូលថ្វាយព្រះមហាក្សត្រ នៃ
ព្រះរាជាណាចក្រកម្ពុជាសូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

**អគ្គសចនករ**

**ហត្ថលេខា**

**អ៊ឹត ឈន**

លេខ: ៧០៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ារ៉ាសី សំរិន

Downloaded from http://www.khmerlaws.com

## អគ្គសចនការ

សក្តិកអាវ



ភ្ជាប់ជាមួយព្រះរាជក្រឹត្យលេខ នស/រកត/០៩០២/២៧៧
ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០២ ត្រឹមត្រូវតាមច្បាប់ដើម

សក្តិស្មា



សក្តិដៃអាវ



Downloaded from http://www.khmerlaws.com

## អគ្គសវនករង

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/២៧៧
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ




Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០២/២៧៧
ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ

## អគ្គលេខាធិការ

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ



3

Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០២/២៧៧
ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃថ្នាក់ដឹកនាំអាជ្ញាធរសវនកម្មជាតិ

## អគ្គលេខាធិការរង

សក្តិកអាវ



សក្តិស្មា



សក្តិដៃអាវ



Downloaded from http://www.khmerlaws.com

## ឯកសណ្ឋានផ្លូវការ

នស/រកត/០៩០២/២៧៧

៣០ កញ្ញា ២០០២



Downloaded from http://www.khmerlaws.com

## ឯកសណ្ឋានប្រពៃណី

ឧបសម្ព័ន្ធទី២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០២/២៦៧
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីសញ្ញាសក្តិ
និង ឯកសណ្ឋាន នៃថ្នាក់ដឹកនាំរាជការសេវាកម្មជាតិ



6

Downloaded from http://www.khmerlaws.com